# ៥. ការដាំបញ្ចូលនៅក្នុងតំបន់ដែលធ្វើអាជីវកម្មហើយ*

## ៥.១ យុត្តិកម្ម

វិធីសាស្ត្រនេះត្រូវបានគេនិយមប្រើប្រាស់ជាទូទៅនៅក្នុងដំណុះព្រៃស្រោងក្រោយការធ្វើអាជីវកម្មហើយ ដោយការដាំបញ្ចូលនូវប្រភេទឈើក្នុងស្រុកដែលមានតំលៃពាណិជ្ជកម្មខ្ពស់ដែលសំខាន់គឺអំបូរឈើទាល ។អំបូរឈើទាល បានបង្ហាញឱ្យឃើញនូវបំរែបំរួលក៏រិតអត្រារស់យ៉ាងធំ ហើយជាទូទៅកូនឈើដែលបានដាំនៅក្រោមគំរបម្លប់ដោយផ្នែក មានអត្រារស់ខ្ពស់ជាងកូនឈើដែលដាំនៅក្រោមពន្លឺថ្ងៃពេញ ។

បទពិសោធន៍នានាក្នុងការអនុវត្តនូវវិធីសាស្ត្រនេះបានបង្ហាញថាមានបំរែបំរួលខុសៗគ្នា (Adjers *et al.*, 1995) ។ លទ្ធផលអាចឱ្យទុកចិត្តបាននៅទីណាដែលមានការយកចិត្តទុកដាក់ក្នុងការប្រើប្រាស់កូនឈើដែលល្អៗ ហើយពពួកស្មៅ និងគំរបរុក្ខជាតិដែលគ្របពីលើត្រូវបានត្រួតពិនិត្យ ។ នៅក្នុងករណីផ្សេងទៀតដែលគំរបម្លប់ក្រាស់ខ្លាំងពេក កូនឈើដែលបានដាំមានសភាពក្រិន ឬដោយមានការប្រកួតប្រជែងពីស្មៅ ដែលធ្វើឱ្យគំរោងការងារទាំងមូលទទួលបរាជ័យ (Ramos & Delamo, 1992) ។ វិធីសាស្ត្រនានាគួរត្រូវបានសាកល្បងសំរាប់ទីតាំងជាក់លាក់និមួយៗ ។ វិធីសាស្ត្រនេះ ប្រហែលជាពិបាកនឹងអនុវត្តន៍នៅក្នុងដំណុះព្រៃដុះឡើងវិញដែលមានអាយុចំណាស់ ដោយសារគំរបនៃពពួករុក្ខជាតិដែលបោះទីតាំងមុនមានសភាពក្រាស់ពេក ។

## ៥.២. ការអនុវត្តន៍

### ៥.២.១ ការដាំតាមខ្សែប្រលោះព្រៃ

- ខ្សែប្រលោះព្រៃសំរាប់ដាំឈើគួរត្រូវបើកក្នុងគំលាត ១០ម ឬធំជាងនេះ ។ ខ្សែប្រលោះព្រៃនេះ ត្រូវបើកក្នុងប្រវែងទទឹង ២ម ហើយចំណុចដែលត្រូវដាំកូនឈើត្រូវដាក់សញ្ញាសំគាល់ក្នុងចំងាយ ៣ម មួយ ។
- ប្រភេទឈើមិនមែនពាណិជ្ជកម្ម ពពួកគុម្ពព្រឹក្ស និង រុក្ខជាតិស្រទាប់ក្រោមផ្សេងៗទៀតនៅតាមខ្សែប្រលោះព្រៃត្រូវកាប់សំអាតចេញ ។ ដើមឈើនៃប្រភេទមិនមានតំលៃពាណិជកម្មត្រូវក្រៀវដោយជ្រើសរើស ដើម្បីបើកគំរបព្រៃផ្តល់ពន្លឺដល់កូនឈើ ។
- គួរតែប្រើប្រាស់កូនឈើដែលមានកំពស់ខ្ពស់ៗ ដែលបានបណ្តុះនៅក្នុងស្បោងប្លាស្ទិកខ្មៅ ព្រោះពួកវាអាចមានឱកាសរស់ដោយប្រជែងនឹងស្មៅ ។
- ទិសនៃខ្សែប្រលោះព្រៃខុសៗគ្នាត្រូវបានប្រើប្រាស់ ។ សំរាប់ភាពងាយស្រួលក្នុងការអនុវត្តន៍ការងារ យកល្អត្រូវបើកប្រលោះព្រៃក្នុងទិសកែងនឹងផ្លូវចេញចូលសំខាន់ៗដើម្បីឱ្យមានភាពងាយស្រួលក្នុងការពង្រាយ

---

*(*): ផ្នែកនេះត្រូវបានដកស្រង់ និង សំរួលពី Carles Garcia and Jan Falck. 2003.*

- កូនឈើ និងងាយស្រួលក្នុងការស្វែងរកកូនឈើនៅក្នុងរយៈពេលថែទាំ។

ការសំរេចចិត្តលើការបើកទំហំទទឹងប្រលោះព្រៃ ពេលវេលានៃការបើក ។ល។ គឺជាបញ្ហានៃការសិក្សាស្រាវជ្រាវនៅក្នុងទីតាំងមួយជាក់លាក់និងសំរាប់ប្រភេទឈើមួយ(ឬក្រុមប្រភេទមួយ)ជាក់លាក់។ ឧទាហរណ៍ពីឡូតិ៍ពិសោធន៍រយៈពេល ១៥ ឆ្នាំនៅក្នុងព្រៃបំរុងទុកតាប៉ាស់ប្រទេសម៉ាឡេស៊ីបានបង្ហាញថាការក្រៀវដើម ឈើដើម្បីបើក ពន្លឺថ្ងៃដល់កូនឈើអំបូរឈើទាលក្នុងរយៈពេលខុសៗគ្នា មានឥទ្ធិពលខុសៗគ្នាទៅលើការដុះ លូតលាស់នៃកូនឈើដាំ។ ប្រព្រឹត្តកម្មដែលបានអនុវត្តគឺការក្រៀវដើមឈើដោយប្រើថ្នាំបំពុលគ្រប់ដើមឈើ ទាំងអស់ក្នុងចំងាយពី ០.៩-១.៨ម សងខាងខ្សែប្រលោះព្រៃ។ លទ្ធផលបង្ហាញថា គេត្រូវបើកគំរបព្រៃនៅពេលដាំកូនឈើឬក៏នៅរយៈពេលបីខែបន្ទាប់ពីដាំ។

### ៥.២.២ ការដាំតាមប្រលោះព្រៃ

ចំពោះការដាំឈើតាមប្រលោះព្រៃ មានវិធីសាស្ត្រជាច្រើនត្រូវបានគេសាកល្បងនៅក្នុងទីកន្លែងផ្សេងៗគ្នាព្រមទាំងបានលទ្ធផលខុសៗគ្នាផងដែរ។ ខាងក្រោមនេះជាឧទាហរណ៍មួយរបស់លោក Carles Garcia and Jan Falck (2003):

- បង្កើតឡូតិ៍ទំហំ ២០ម x ២០ម តាមរយៈការបើកខ្សែប្រលោះព្រៃក្នុងចំងាយ ២០ម មួយ។ ដោតបង្គោលចំងាយ ២០ម មួយ នៅតាមខ្សែប្រលោះព្រៃ ហើយបង្គោលនេះបង្កើតបានជាចំណុចផ្ចិតនៃឡូតិ៍ដែលមានទំហំ ២០ម x ២០ម ហើយការេនិមួយៗនេះត្រូវបែងចែក បន្តទៀតទៅជា អនុឡូតិ៍ទំហំ ១០ម x ១០ម។
- នៅក្នុងអនុឡូតិ៍នេះ ប្រលោះព្រៃត្រូវបានបង្កើតនៅក្នុងទីតាំងសមស្រប។ ក្រុមអ្នកបើកប្រលោះព្រៃត្រូវធ្វើការសំរេចចិត្តថាតើគេត្រូវការដាំឈើឬទេនៅក្នុងកូនការេនិមួយៗដោយផ្អែកលើវត្តមាន និង អវត្តមាននៃដំណុះឈើដោយធម្មជាតិ។
- ប្រសិនបើមានកូនឈើនៃប្រភេទពាណិជ្ជកម្មដែលដុះដោយធម្មជាតិតិចជាង ៥ ដើមក្នុងអនុឡូតិ៍និមួយៗនោះគេត្រូវដាំឈើ។ នៅក្នុងប្រលោះព្រៃដែលមានទំហំអង្កត់ផ្ចិត ប្រហែល ៣-៤ម កូនឈើ ៣ ដើមត្រូវដាំ នៅក្នុងចំងាយ ១-១.៥ម ពីផ្ចិតនៃប្រលោះព្រៃ។
- ការជ្រើសរើសប្រលោះព្រៃនៅក្នុងអនុឡូតិ៍និមួយៗ គឺជាភារកិច្ចរបស់ក្រុមការងារដែលផ្អែកលើលក្ខណៈសម្បត្តិ មួយចំនួនដូចខាងក្រោម:
    - ជ្រើសរើសទីតាំងណាដែលមានប្រលោះព្រៃរួចហើយ ដើម្បីជៀសវាងការបើកប្រលោះព្រៃច្រើន
    - ទីតាំងដែលត្រូវដាំឈើត្រូវមានលក្ខណៈសមស្រប ដូចជាត្រូវជៀសវាងពីផ្ទាំងថ្ម ផ្លូវទឹក ជំរាលខ្លាំងព្រឹង នៃគល់ឈើធំៗ ។ល។
    - បើគ្មានប្រលោះព្រៃដោយធម្មជាតិទេត្រូវបើកប្រលោះព្រៃដោយក្រៀវដើមឈើដែលឥតប្រយោជន៍ចោល

តាមវិធីនេះទាមទារឱ្យមានការកាប់បើកប្រលោះព្រៃយ៉ាងហោចណាស់ពីរលើក ។ លើកទីមួយបន្ទាប់ពីដាំឈើ ១-២ឆ្នាំហើយលើកទីពីរបន្ទាប់ពី ៤ ឆ្នាំ ។ ការកំណត់ពេលវេលាសមស្របដើម្បីបើក គំរបព្រៃគឺជាវិធីសាស្ត្រ រុក្ខវប្បកម្មមួយដែលចាំបាច់ដើម្បីធានានូវអត្រារស់ខ្ពស់និងការដុះលូតលាស់ល្អ ។ការពន្យារពេលក្នុងការបើកគំរបព្រៃ នឹងធ្វើឱ្យកូនឈើអន់គុណភាព ។







ការកំណត់អំពីទទឹងនៃខ្សែប្រលោះព្រៃ និងទំហំប្រលោះព្រៃដើម្បីឱ្យកូនឈើដុះលូតលាស់បានសមស្របគឺជាកិច្ចការមួយដែលឋិតនៅជាបញ្ហាចំបងសំរាប់អ្នកគ្រប់គ្រងការងារដាំឈើ ។ ជាទូទៅគេបានដឹងថា ការបើកប្រលោះព្រៃឱ្យធំមានលក្ខណៈប្រសើរប៉ុន្តែត្រូវចំណាយសោហ៊ុយច្រើន ហើយអាចមានបញ្ហាអំពីការប្រកួតប្រជែងដោយស្មៅនិងរុក្ខជាតិឥតប្រយោជន៍ផ្សេងៗ ។

ទាំងការដាំឈើដោយបើកខ្សែប្រលោះព្រៃ និង ដាំក្នុងប្រលោះព្រៃ សុទ្ធតែជាវិធីសាស្ត្រសមស្រប ប៉ុន្តែបទពិសោធន៍បង្ហាញថាកូនឈើដែលដាំដោយបើកខ្សែប្រលោះព្រៃហាក់ទទួលពន្លឺថ្ងៃមិនគ្រប់គ្រាន់សំរាប់ការដុះលូតលាស់របស់វា ចំណែកឯការដាំឈើក្នុងប្រលោះព្រៃ មានប្រសិទ្ធិភាពជាងទាំងការចំណាយ និងការទប់ស្កាត់ការដុះលូតលាស់នៃពពួករុក្ខជាតិស្រទាប់ក្រោម ។

***សូមប្រើប្រាស់ទំព័របន្ថែម និង ឧបសម្ព័ន្ធនានាដូចខាងក្រោម:***

ឧបសម្ព័ន្ធទី ១: ការជ្រើសរើសប្រភេទឈើ

ឧបសម្ព័ន្ធទី ២: លទ្ធកម្មគ្រាប់ពូជ

ឧបសម្ព័ន្ធទី ៣: ការងារនៅថ្នាលបណ្តុះកូនឈើ

ឧបសម្ព័ន្ធទី ៤: ការងារនៅចំការដាំឈើ

ឧបសម្ព័ន្ធទី ៥: ការថែរក្សាចំការឈើដាំ

ឧបសម្ព័ន្ធទី ១០: ប្រភេទឈើមួយចំនួនដែលផ្តល់ផលិតផលបន្ថែមក្រៅពីឈើ

ទំព័របន្ថែមទី ១: ការធ្វើផែនការគ្រប់គ្រងចំការឈើដាំ